មាត្រា ១០.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង គណៈកម្មាធិការជាតិបណ្តុះបណ្តាល មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋម ន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ុង ហួត ហ៊ុន សែន

***

**អនុក្រឹត្យលេខ ១៩ អនក្រ បក**

**ស្តីពី**

**ការលុបអនុក្រឹត្យលេខ ៣០ អនក្រ .បក**

**ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ១៩៩៧ដែលស្តីពីការរៀបចំ**

**ឲ្យដំណើរការឡើងវិញនូវក្រុមហ៊ុនអាកាសចរកម្ពុជា**

*****

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៩៩៧/១៩៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាល

-យោងតាមសំណូមពរចាំបាច់

**សំរេច**

មាត្រា ១.- អនុក្រឹត្យលេខ៣០ អនក្រ/បក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ ដំណើរការឡើងវិញនូវក្រុមហ៊ុនអាកាសចរកម្ពុជា (KAMPUCHEA AIRLINE) អក្សរកាត់ (KAL) ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២.- អនុញ្ញាត ឲ្យក្រុមហ៊ុនអាកាសចរកម្ពុជា ( KAMPUCHEA AIRLINES) អក្សរកាត់ (KAL) រៀបចំបែបបទ ដើម្បីឲ្យក្រុមហ៊ុននេះប្រែក្លាយទៅជាក្រុមហ៊ុនឯកជន ។

www.pheakdeylaw.com

មាត្រា ៣.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរកម្ពុជា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រុមហ៊ុនអាកាសចរកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ុង ហួត ហ៊ុន សែន

***

**អនុក្រឹត្យលេខ ៧៦ អនក្រ តត**

**ស្តីពី ការជូនមេដាយស្ហាមនាជាតិ**

****

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ការប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៩៩៧/១៩៧ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-តាមសំណើរបស់សមាគមឥស្លាមកម្ពុជា

**សម្រេច**

**មាត្រា ១.-** ត្រូវបានប្រគល់ **មេដាយមាសស្ហាមនាជាតិ** ជូនសប្បុរសជន ០១រូប និងអ្នកចលនា សប្បុរសជន ០១រូប ដែលបានជួយកសាងអាគារសិក្សាមួយខ្នងនៅភូមិអង្គរបាន ឃុំអង្គរបាន ស្រុកកងមាស ខេត្តកំពង់ចាម ដូចមាននាយនាមខាងក្រោម :

១-ដាតុបាដ្ឋី បាគសាន់ ប៊ិន ហាជ្ជីតាំពី ជនជាតិម៉ាឡេស៊ី បរិច្ចាគទឹកប្រាក់ ២២.៥៥០ ដុល្លារអាមេរិក

២-លោក ម៉ូហាំមាត់ ប៊ិន ម៉ារវ៉ាន អគ្គលេខាសមាគមឥស្លាមកម្ពុជា ជាអ្នកចលនា សប្បុរសជន

www.pheakdeylaw.com